# Bloodborne Pathogen (ភ្នាក់ងារបង្ករោគក្នុងឈាម)៖ *អ្វីដែលអ្នកត្រូវដឹង*



Bloodborne Pathogens (ភ្នាក់ងារបង្ករោគក្នុងឈាម,BBPs) គឺជាមេរោគដែលឆ្លងរាលដាលតាមរយៈឈាម និងសារធាតុរាវក្នុងរាងកាយផ្សេងទៀត។ មេរោគទាំងនេះអាចបង្កជាជំងឺធ្ងន់ធ្ងរដូចជាជំងឺរលាកថ្លើម ឬមេរោគអេដស៍ ដូច្នេះចាំបាច់ត្រូវដឹងពីរបៀបរក្សាសុវត្ថិភាព។

## ការបង្ការមេរោគ

- ប្រព្រឹត្តចំពោះឈាម ឬសារធាតុរាវក្នុងរាងកាយទាំងអស់ហាក់បីដូចជាមានការបង្កមេរោគ។
- ពាក់ស្រោមដៃជានិច្ចពេលកាន់ចាត់ចែងឈាម ឬសារធាតុរាវក្នុងរាងកាយ។ ស្វែងយល់ពីរបៀបដោះស្រោមដៃអាចបោះចោលបានដោយសុវត្ថិភាពនៅលើវិបសាយ **https://www.redcross.org/content/dam/redcross/atg/PDFs/Take_a_Class/Bloodborne-Pathogens-Fact-and-Skill-Sheets.pdf?srsltid=AfmBOop5pOSzS-0e-OiWQGBRGbfbvhI4wTxu-rK7i157Fa0MP2gKF5se**
- លាងដៃរបស់អ្នកឱ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹក។
- រុំបង់មុខរបួស និងស្នាមរបួស។
- កុំប្រើម្ជុល ឬរបស់ផ្ទាល់ខ្លួនរួមគ្នា ដូចជាឡាមជាដើម។

## ការចម្លងមេរោគ (របៀបដែល BBPs ឆ្លងរាលដាល)

- BBPs ឆ្លងរាលដាលនៅពេលដែលឈាម ឬសារធាតុរាវក្នុងរាងកាយដែលមានមេរោគឆ្លងចូលទៅក្នុងខ្លួនមនុស្សម្នាក់ទៀត។
- ការប៉ះពាល់ផ្ទាល់៖ ឈាម ឬសារធាតុរាវក្នុងរាងកាយដែលមានមេរោគពីមនុស្សម្នាក់ចូលទៅក្នុងខ្លួនរបស់មនុស្សម្នាក់ទៀត ដូចជាឈាមមានឆ្លងមេរោគខ្ទាតចូលភ្នែក។
- ការប៉ះពាល់ដោយប្រយោល៖ ស្បែករបស់មនុស្សម្នាក់ប៉ះវត្ថុដែលមានឈាម ឬសារធាតុរាវក្នុងរាងកាយដែលមានមេរោគ ដូចជាយកសម្លៀកបំពាក់ប្រឡាក់ឈាម ឬសារធាតុរាវក្នុងរាងកាយចេញពីខ្លួននរណាម្នាក់ដែលមានជំងឺ។
- ការចម្លងមេរោគពីតំណក់ទឹកតូចៗតាមផ្លូវដង្ហើម៖ មនុស្សម្នាក់ហឺតស្រូបចូលនូវដំណក់ទឹកតូចៗពីនរណាម្នាក់ដែលមានជំងឺ ដូចជាតាមរយៈការក្អក ឬកណ្តាស់។
- ការចម្លងមេរោគតាមភ្នាក់ងារចម្លង៖ ស្បែកមនុស្សត្រូវបានជ្រៀតចូលដោយប្រភពឆ្លងរោគ ដូចជាសត្វល្អិតខាំ។

## ការគ្រប់គ្រងការឆ្លងមេរោគ (ការរក្សាសុវត្ថិភាព)

- ប្រើស្រោមដៃ និងឧបករណ៍ការពារ នៅពេលជួយអ្នកដែលកំពុងហូរឈាម។
- សម្អាតឈាមដែលកំពប់ឲ្យបានត្រឹមត្រូវដោយប្រើថ្នាំសម្លាប់មេរោគ ឬទឹកអូសារ៉ែល 10%។ ដើម្បីធ្វើទឹកអូសារ៉ែល សូមឆែកមើលការណែនាំនៅលើដបទឹកអូសារ៉ែល។ ប្រសិនបើមិនមានការណែនាំទេ អ្នកអាចលាយវាដោយខ្លួនឯងដោយប្រើ 1/3 ពែងនៃ ទឹកអូសារ៉ែរ សម្រាប់ក្នុងមួយហ្គាឡុងនៃទឹកដែលមានសីតុណ្ហភាពនៅក្នុងបន្ទប់។
- ដាក់អ្វីទាំងអស់ដែលប្រឡាក់ឈាមនៅលើវានៅក្នុងថង់របស់វាផ្ទាល់។
- បោះចោលវត្ថុមុតស្រួច ដូចជាម្ជុល ក្នុងធុងសំរាមពិសេស (ជាធម្មតាធុងជ័រពណ៌ក្រហមដែលមានគម្របបិទជិត និងមានសម្គាល់ថាគ្រោះថ្នាក់ជីវសាស្ត្រ)។
- អនុវត្តតាមច្បាប់សុវត្ថិភាពនៅកន្លែងធ្វើការ ដើម្បីការពារខ្លួនអ្នក និងអ្នកដទៃ។

Washington State Department of
CHILDREN, YOUTH & FAMILIES

## ការព្យាបាល

- ការឆ្លងមេរោគ BBP មួយចំនួនដូចជាជំងឺរលាកថ្លើមប្រភេទ C អាចនឹងមានការព្យាបាល ឬការព្យាបាលឲ្យជាដាច់។ មេរោគផ្សេងទៀត ដូចជាមេរោគអេដស៍ មានថ្នាំដែលជួយមនុស្សឱ្យរស់នៅបានយូរ និងមានសុខភាពល្អជាងមុន។
- បើអ្នកណាម្នាក់ទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រកាន់តែឆាប់ នោះលទ្ធផលកាន់តែល្អ។
- លាងសម្អាតស្នាមរបួស មុខរបួស និងស្បែកដែលបានប៉ះពាល់ឱ្យបានស្អាតជាមួយសាប៊ូ និងទឹក។
- ប្រសិនបើមានខ្ទាតប្រឡាក់ឈាម ឬសារធាតុដែលអាចចម្លងមេរោគជុំវិញមាត់ ឬច្រមុះ ត្រូវបាញ់ទឹកលាងសម្អាតតំបន់នោះ។
- បើខ្ទាតចូលភ្នែក ឬខ្ទាតប៉ះជុំវិញភ្នែក ត្រូវលាងជម្រះជាមួយទឹកស្អាត សេរ៉ូមប្រៃ ឬសូលុយស្យុងសម្រាប់លាងជម្រះ រយៈពេល 20 នាទី។
- ប្រសិនបើត្រូវការ emergency medical services (សេវាវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់, EMS) ត្រូវរាយការណ៍ព័ត៌មានលម្អិតអំពីអ្វីដែលបានកើតឡើងដល់បុគ្គលិក។ រាយការណ៍ពីឧប្បត្តិហេតុនេះទៅកាន់បុគ្គលិកកាន់ករណីដែលបានចាត់តាំង។
- កត់ត្រាឧប្បត្តិហេតុដោយសរសេរព័ត៌មានលម្អិតអំពីអ្វីដែលបានកើតឡើង។

## ការធ្វើតេស្ត

ការធ្វើតេស្តឈាមអាចរកការឆ្លងមេរោគ BBP។ ប្រសិនបើអ្នកប្រហែលជាបានប៉ះពាល់ ត្រូវទៅធ្វើតេស្តឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ដំបូង BBPs ជាច្រើនមិនបង្ហាញរោគសញ្ញាទេ ដូច្នេះការធ្វើតេស្តគឺសំខាន់។

## ការសម្ងាត់

កំណត់ត្រាវេជ្ជសាស្ត្រ រួមទាំងលទ្ធផលតេស្ត BBP គឺមានលក្ខណៈឯកជន។ អ្នកមិនត្រូវបានអនុញ្ញាតឱ្យចែករំលែកស្ថានភាពឆ្លងមេរោគរបស់កុមារទេ។ ប្រសិនបើអ្នក ឬកូននៅក្នុងការថែទាំរបស់អ្នកមាន BBP អ្នកនៅតែមានសិទ្ធិ និងទទួលបានការការពារ។ បុគ្គលិក និងសាលាមិនអាចចែករំលែកព័ត៌មានសុខភាពរបស់អ្នកដោយគ្មានការអនុញ្ញាតបានទេ។

## ធនធានបន្ថែម

ភ្នាក់ងារបង្ករោគក្នុងឈាម – វិញ្ញាបនបត្របញ្ជាក់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ CY25៖ **https://cpe.socialwork.uw.edu/alliance-courses/content/bloodborne-pathogens-cy25-certification-elearning**